*ប្រព័ន្ធការពារ និងការតស៊ូមតិរបស់រដ្ឋកាលីហ្វ័រនីញ៉ា*

# ការយល់ដឹងអំពីច្បាប់លែនធឺមែន-ធីទ្រីស-ហ្ស៊ត (LPS, Lanterman-Petris-Short)

ការបោះពុម្ពផ្សាយលេខ **#5608.06-Cambodian**

## ជំពូកទី 3 ៖ សិទ្ធិរបស់អ្នកស្ថិតក្រោមច្បាប់ LPS

ស្ថិតក្រោមច្បាប់ Lanterman-Petris-Short (LPS) Act និងច្បាប់ផ្សេងទៀត បើទោះបីជាអ្នកទទួលបានការព្យាបាលដោយមិនបានតាំងចិត្តក៏ដោយ ក៏អ្នករក្សាបាននូវសិទ្ធិមួយចំនួនរបស់អ្នកជម្ងឺ ។ ឧទាហរណ៍ តាមច្បាប់ អ្នកមានសិទ្ធិទទួលបានការព្យាបាលតម្រូវតាមស្ថានភាពរបស់អ្នក ដែលមានភាពតឹងតែងតិចតួចបំផុតចំពោះសេរីភាពផ្ទាល់ខ្លួនរបស់អ្នក ។ អ្នកមានសិទ្ធិប្រើទូរស័ព្ទ និងមានសិទ្ធិទទួលភ្ញៀវ ។ WIC § 5325 ។ អ្នកក៏មានសិទ្ធិដែលច្បាប់រដ្ឋា ភិបាលរដ្ឋ និងច្បាប់រដ្ឋាភិបាលសហព័ន្ធប្រគល់ឲ្យ ដូចគ្នានឹងពលរដ្ឋដទៃទៀតដែរ ក្នុងពេលអ្នកកំពុងទទួលបានការព្យាបាល បូករួមទាំងសិទ្ធិទទួលបានការព្យាបាលផ្ដួសាស្រ្ត ព្រមទាំងសិទ្ធិទទួលបានការព្យាបាលប្រកបដោយភាពថ្លៃថ្នូរ ។ WIC § 5325.1 ។

នៅក្នុងច្បាប់ LPS គឺមានសិទ្ធិពីរយ៉ាង ៖ (1)សិទ្ធិដែលមិនអាចបដិសេធបាន និង (2) សិទ្ធិដែលអាចបដិសេធបាន តែអាចបដិសេធបានតែក្នុងករណីដែលមាន “មូលហេតុច្បាស់លាស់” ប៉ុណ្ណោះ។ នៅពេលដែលសិទ្ធិរបស់អ្នកត្រូវបានបដិសេធ ដោយសារមូលហេតុច្បាស់លាស់ គឺត្រូវបដិសេធក្នុងលក្ខណៈដែលមានភាពរឹតត្បិតដ៏តិចតួចបំផុត ។ សិទ្ធិរបស់អ្នក និងពេលដែលសិទ្ធិនោះត្រូវបដិសេធ មានរៀបរាប់ខាងក្រោម ។

មន្ទីរព្យាបាលថែទាំជម្ងឺផ្លូវចិត្ត ក៏ត្រូវតែអនុវត្តតាមសិទ្ធិរបស់អ្នកជម្ងឺ ដែលមានចែងនៅក្នុងក្រមសុខុមាលភាព និងក្រមវិទ្យាស្ថានរដ្ឋកាលីហ្វ័រនីញ៉ា (WIC, Welfare & Institutions Code) ដែរ។

## សិទ្ធិដែលមិនអាចបដិសេធបាន

WIC § 5325.1 បានចែងថា “មនុស្សដែលមានជម្ងឺផ្លូវចិត្ត មានសិទ្ធិស្របច្បាប់ និងការទទួលខុសត្រូវដូចគ្នានឹងសិទ្ធិដែលផ្តល់ឲ្យមនុស្សទូទៅ ពីសំណាក់រដ្ឋធម្មនុញ្ញ និងច្បាប់សហព័ន្ធ ព្រមទាំងរដ្ឋធម្មនុញ្ញ និងច្បាប់របស់រដ្ឋកាលីហ្វ័រនីញ៉ា ប្រសិនបើមិនមានការដាក់កំហិតជាក់លាក់ពីច្បាប់ និងបទបញ្ញត្តិរបស់សហព័ន្ធ និងរដ្ឋទេនោះ” ។

សិទ្ធិទាំងអស់នេះរួមមាន តែមិនកំណត់តែចំពោះ ៖

- សិទ្ធិទទួលបានសេវាកម្មការព្យាបាល ដែលលើកកម្ពស់ សក្តានុពលនៃបុគ្គលនោះឲ្យអាចធ្វើអ្វីៗបានដោយឯករាជ្យ ។ ការព្យាបាល ត្រូវធ្វើឡើងក្នុងវិធីដែលមានភាពរឹតបន្តឹងតិចតួចចំពោះសេរីភាពផ្ទាល់ខ្លួនរបស់មនុស្សម្នាក់ៗ ។
- សិទ្ធិទទួលបានភាពថ្លៃថ្នូរ ឯកជនភាព និងការថែទាំបែបមនុស្សជាតិ ។
- សិទ្ធិរួចផុតពីការធ្វើបាប បូករួមទាំងការរឹតបន្តឹងផ្នែករាងកាយដោយមិនសមហេតុផល ឬហួសហេតុ ការដាក់ឲ្យនៅឯកោ ការប្រើថ្នាំព្យាបាលជម្ងឺ ការប្រព្រឹត្តរំលោភ ឬការទុកចោលដោយមិនយកចិត្តទុកដាក់ ។ ការប្រើថ្នាំព្យាបាល មិនត្រូវយកមកប្រើដើម្បីជាការដាក់ពិន័យ សម្រាប់ភាពងាយស្រួលរបស់បុគ្គលិក ជាការជំនួសកម្មវិធីការព្យាបាល ឬធ្វើឡើងក្នុងបរិមាណដែលបង្កការរំខានដល់កម្មវិធីព្យាបាល ។

- សិទ្ធិទទួលបានការថែទាំ និងការព្យាបាលតាមវេជ្ជសាស្ត្រភ្លាមៗ ។
- សិទ្ធិទទួលបានសេរីភាព និងការអនុវត្តផ្នែកសាសនា។
- សិទ្ធិក្នុងការចូលរួមកម្មវិធីសមរម្យ ចំពោះការអប់រំដែលគាំទ្រជាសាធារណៈ ។
- សិទ្ធិចំពោះអន្តរកម្មសង្គម និងការចូលរួមសកម្មភាពសហគមន៍ ។
- សិទ្ធិចំពោះការធ្វើលំហាត់ប្រាណរាងកាយ និងឱកាសចំពោះការលំហែកាយ ។
- សិទ្ធិរួចផុតពីការប្រើទម្រង់ការប្រកបដោយគ្រោះថ្នាក់ ។
- សិទ្ធិបដិសេធការព្យាបាលខួរក្បាល (ការវះកាត់ខួរក្បាល) ។
- សិទ្ធិដើម្បីមើល និងទទួលបានសេវាកម្មចំពោះការតស៊ូមតិសម្រាប់អ្នកជម្ងឺ ដែលមិនមានការទទួលខុសត្រូវដោយផ្ទាល់ ឬដោយប្រយោលផ្នែកគ្លីនិក ឬផ្នែករដ្ឋបាលសម្រាប់អ្នកដែលទទួលបានសេវាកម្មថែទាំសុខភាពផ្លូវចិត្ត ។

សិទ្ធិទាំងអស់ខាងលើ ស្ថិតនៅជាបុគ្គលជាសាម៉ីខ្លួន ហើយក៏មិនប៉ះពាល់ដោយការតែងតាំងពីតុលាការឲ្យមានអ្នកជួយមើលថែទាំអ្នកជម្ងឺ ហើយអាចអនុវត្តបានទាំងចំពោះអ្នកជម្ងឺដែលស្ម័គ្រចិត្ត និងមិនស្ម័គ្រចិត្តទទួលការថែទាំ ។ WIC §§ 5325, 5325.1 ។

ដូចអ្វីដែលបានពិភាក្សាកន្លងមក សិទ្ធិមួយចំនួនស្ថិតក្រោមច្បាប់ WIC § 5325 អាចត្រូវបដិសេធចោល តែការបដិសេធទាំងអស់នេះអាចធ្វើទៅបានលុះត្រាតែមានការចងចក្រងជាឯកសារបានត្រឹមត្រូវ ដែលមានបង្ហាញមូលហេតុសមរម្យ ។ WIC § 5326 ។ ទោះជាយ៉ាងណាក៏ដោយ **សិទ្ធិដែលស្ថិតក្រោម § 5325.1 អាចមិនត្រូវបានគេដកហូតឡើយ** ហើយការពិន័យចំពោះការរំលោភសិទ្ធិទាំងអស់នេះដោយចេតនាគឺមានរួមបញ្ចូលទាំងការពិន័យផ្នែករដ្ឋប្បវេណី និងការដកហូតអាជ្ញាប័ណ្ណ ក៏ដូចជាការពិន័យចំពោះសកម្មភាពរបស់បុគ្គលដែលធ្វើឲ្យខូចខាតមន្ទីរព្យាបាលថែទាំ ។ WIC § 5326.9(d)-(e) ។

# ការបដិសេធសិទ្ធិដោយមានមូលហេតុសមរម្យ

សិទ្ធិមួយចំនួនស្ថិតក្រោមច្បាប់ LPS អាចត្រូវបានបដិសេធចោល ដោយមាន "មូលហេតុសមរម្យ" ដែលមានន័យថា មន្ទីរថែទាំព្យាបាល មិនអាចបដិសេធសិទ្ធិរបស់អ្នកដោយមិនមានការបង្ហាញមូលហេតុមួយ ក្នុងចំណោមមូលហេតុដ៏តិចតួចដែលគេអាចចាត់ទុកជាបានការ ។ ខាងក្រោមគឺជាបញ្ជីនៃសិទ្ធិ ដែលអាចត្រូវបដិសេធចោលបើមានមូលហេតុសមរម្យ ។ WIC § 5325 ។

- សិទ្ធិស្លៀកពាក់សម្លៀកបំពាក់ផ្ទាល់ខ្លួន ។
- សិទ្ធិដើម្បីរក្សាទុក និងប្រើប្រាស់របស់ផ្ទាល់ខ្លួន រួមទាំងរបស់សម្រាប់ប្រើប្រាស់ក្នុងបង្គន់ នៅតាមទីកន្លែងដែលអ្នកជម្ងឺអាចចូលបាន ។
- សិទ្ធិដើម្បីរក្សាទុក និងចំណាយប្រាក់ផ្ទាល់ខ្លួនក្នុងចំនួនសមរម្យ ដើម្បីទិញដូរតិចតួច ។
- សិទ្ធិប្រើកន្លែងទុកដាក់ឥវ៉ាន់ផ្ទាល់ខ្លួន សម្រាប់ការប្រើប្រាស់ជាលក្ខណៈឯកជន ។
- សិទ្ធិជួបភ្ញៀវប្រចាំថ្ងៃ ។
- សិទ្ធិប្រើទូរស័ព្ទតាមភាពសមរម្យ ដើម្បីហៅទូរស័ព្ទចេញ និងទទួលការហៅទូរស័ព្ទចូលជាសម្ងាត់ ឬឲ្យគេហៅទូរស័ព្ទចំពោះការប្រើប្រាស់បែបនេះសម្រាប់អ្នកជម្ងឺ ។
- សិទ្ធិប្រើសម្ភារៈសម្រាប់សរសេរសំបុត្រ ប៉ូករួមទាំងតែម ព្រមទាំងការផ្ញើសំបុត្រ និងការទទួលសំបុត្រដែលមិនត្រូវបានគេបើកស្រោមពិនិត្យជាមុន ។
- សិទ្ធិផ្សេងៗទៀត ដូចអ្វីដែលមានបញ្ជាក់ក្នុងបទបញ្ញត្តិ ។

សិទ្ធិទាំងអស់ដែលបានបញ្ជាក់ក្នុង WIC § 5325 មិនអាចត្រូវលើកលែងដោយឪពុកម្តាយ អាណាព្យាបាល អ្នកមើលថែទាំតាមការតែងតាំងរបស់អ្នកជម្ងឺបានឡើយ ។

បើទោះបីជាអ្នកជម្ងឺមានសិទ្ធិបដិសេធការព្យាបាលបែបកន្ត្រាក់ក៏ដោយ សិទ្ធិនោះអាចត្រូវបានបដិសេធក្រោមស្ថានភាពមួយដែលគ្មានជម្រើស ដូចអ្វីដែលមានចែងក្នុងច្បាប់ WIC § 5326.7 ។

**សេចក្តីតម្រូវចំពោះការបដិសេធសិទ្ធិអ្នកជម្ងឺដោយមានមូលហេតុសមរម្យ**

ដើម្បីបដិសេធសិទ្ធិរបស់អ្នកជម្ងឺដោយមានហេតុផលសមរម្យ មន្ទីរថែទាំព្យាបាល ត្រូវតែបង្ហាញថាខ្លួនមានហេតុផលសមរម្យដែលត្រូវធ្វើដូច្នោះ ៖

- ការប្រើប្រាស់សិទ្ធិនេះ អាចនាំឲ្យខូចប្រយោជន៍ដល់អ្នកជម្ងឺ ឬ
- វាអាចបង្ករផលប៉ះពាល់ដល់សិទ្ធិរបស់អ្នកដទៃ ឬ
- មន្ទីរថែទាំព្យាបាល អាចនឹងរងការខូចខាតធ្ងន់ធ្ងរ បើសិនជាសិទ្ធិនោះមិនត្រូវបានបដិសេធទេ
- ហើយវាក៏គ្មានវិធីណាដែលល្អជាងនេះ ដើម្បីការពារផលប្រយោជន៍ទាំងបីនេះឡើយ ។

បើបុគ្គលិកបដិសេធសិទ្ធិណាមួយក្នុងចំណោមសិទ្ធិទាំងអស់នេះ មូលហេតុនៃការបដិសេធត្រូវតែពាក់ព័ន្ធដោយផ្ទាល់ចំពោះសិទ្ធិដែលត្រូវបដិសេធចោល ។ បុគ្គលិកប្រចាំមន្ទីរមិនអាចបដិសេធសិទ្ធិរបស់អ្នក ដើម្បីជាការពិន័យ ឬដើម្បីជាការបង្ខំឲ្យអ្នកមានអាកប្បកិរិយាល្អឡើយ ។ 9 C.C.R. § 865.2 ។

ជួនកាលបុគ្គលិករបស់មន្ទីរថែទាំព្យាបាល មានការយល់ច្រឡំថា ពួកគេអាចបដិសេធសិទ្ធិរបស់អ្នក ដើម្បីជាលក្ខ័ណ្ឌក្នុងការទទួលអ្នកចូលព្យាបាលក្នុងមន្ទីរ ជាផ្នែកមួយនៃផែនការព្យាបាល ឬក៏ដោយសារថា អ្នកជម្ងឺ ឬអ្នកដទៃដែលនិយាយជំនួសអ្នកជម្ងឺ បានយល់ព្រមចំពោះការបដិសេធនេះ ។ ក្នុងចំណោមមូលហេតុទាំងនេះ មិនមានមូលហេតុណាមួយស្ថិតក្នុងលក្ខណៈវិនិច្ឆ័យចំពោះមូលហេតុសមរម្យឡើយ ។ ច្បាប់ និងបទបញ្ញត្តិរបស់រដ្ឋាភិបាលរដ្ឋ បានបញ្ជាក់ជូន ដូចខាងក្រោម ៖

- សិទ្ធិទាំងអស់របស់អ្នកជម្ងឺ មិនអាចត្រូវបានបដិសេធ ដើម្បីធ្វើជាលក្ខ័ណ្ឌចំពោះការទទួលអ្នកជម្ងឺចូលក្នុងមន្ទីរ ជាផ្នែកមួយនៃផែនការព្យាបាល ឬដើម្បីជាភាពងាយស្រួលចំពោះបុគ្គលិក សម្រាប់ការដាក់ពិន័យ ឬក៏មិនអាចយកការបដិសេធសិទ្ធិមកធ្វើជាលេសបុព្វសិទ្ធិឡើយ ។ 9 C.C.R. § 865.2(b)(c) ។
- បែបបទនៃការព្យាបាល មិនរាប់បញ្ចូលនូវការបដិសេធសិទ្ធិណាមួយរបស់អ្នកជម្ងឺឡើយ ។ 9 C.C.R. § 865.2(c) ។
- ការលើកលែងសិទ្ធិដែលបានចុះហត្ថលេខាដោយអ្នកជម្ងឺ សាច់ញាតិជាអ្នកទទួលខុសត្រូវចំពោះអ្នកជម្ងឺ អាណាព្យាបាលអ្នកជម្ងឺ ឬអ្នកដែលតុលាការតែងតាំងឲ្យមើលថែទាំអ្នកជម្ងឺ គឺមិនអាចយកមកធ្វើជាលក្ខ័ណ្ឌក្នុងការបដិសេធសិទ្ធិរបស់អ្នកជម្ងឺបានឡើយ ។ 9 C.C.R. § 865.2 (c) WIC § 5325 ។

**សេចក្តីជូនដំណឹង និងការចងក្រងឯកសារអំពីការបដិសេធសិទ្ធិរបស់អ្នកជម្ងឺ**

រាល់ការបដិសេធសិទ្ធិរបស់អ្នកជម្ងឺ ក្នុងបំណងល្អ ត្រូវចងក្រងរក្សាទុកក្នុងកំណត់ត្រាព័ត៌មានព្យាបាលអ្នកជម្ងឺ ។ WIC § 5326 9 C.C.R. § 865.3 ។ ការចងក្រងឯកសារនេះ ត្រូវធ្វើឡើងជាបន្ទាន់ ហើយត្រូវតែធ្វើឡើងឲ្យបានរួចរាល់ ដោយមិនគិតអំពីទម្ងន់ ឬភាពញឹកញាប់នៃការបដិសេធសិទ្ធិឡើយ ។ ក៏មានគោលការណ៍ណែនាំជាក់លាក់ ដើម្បីចងក្រងការបដិសេធបន្ថែមចំពោះសិទ្ធិផងដែរ ក្នុងពេលដែលអ្នកជម្ងឺស្ថិតនៅដាច់ដោយឡែកពីគេ និងស្ថិតក្នុងលក្ខ័ណ្ឌឃុំឃាំងតឹងតែង ។ 9 C.C.R. § 865.4(c) ។

អ្នកជម្ងឺគ្រប់រូប មានសិទ្ធិទទួលបានការពន្យល់ចំពោះការបដិសេធសិទ្ធិនីមួយៗរបស់ពួកគេ ។ ត្រង់នេះ គឺមានន័យថា រៀងរាល់ពេលដែលសិទ្ធិរបស់អ្នកជម្ងឺត្រូវបានបដិសេធ យើងត្រូវប្រាប់ឲ្យអ្នកជម្ងឺបានដឹង ព្រមទាំងប្រាប់ពីមូលហេតុនៃការបដិសេធសិទ្ធិនោះ ។ អ្នកជម្ងឺក៏ត្រូវប្រាប់ឲ្យដឹងអំពីខ្លឹមសារនៃការកត់ត្រាចូលក្នុងកំណត់ត្រាព័ត៌មាននៃការព្យាបាលជម្ងឺរបស់គេផងដែរ ។ 9 C.C.R. § 865.3 ។

រាល់ការបដិសេធសិទ្ធិរបស់អ្នកជម្ងឺ ត្រូវតែកត់ត្រាចូលក្នុងកំណត់ត្រាព័ត៌មាននៃការព្យាបាលរបស់រូបគេ ។ ការកត់ត្រានេះ ត្រូវធ្វើឡើងជាបន្ទាន់ នៅពេលណាដែលសិទ្ធិណាមួយរបស់អ្នកជម្ងឺ ត្រូវបានបដិសេធ ។ ដោយអនុលោមតាម ច្បាប់ 9 C.C.R.., § 865.3 ការកត់ត្រាចងក្រងឯកសារត្រូវរួមបញ្ចូលនូវ ៖

- កាលបរិច្ឆេទ និងពេលវេលាដែលសិទ្ធិ ត្រូវបានបដិសេធ
- សិទ្ធិជាក់លាក់ដែលបានបដិសេធ

- មូលហេតុសមរម្យចំពោះការបដិសេធនូវសិទ្ធិ ដោយបូករួមទាំងវិធីយកមកប្រើ ឬយកមកសាកល្បង ដែលមានការរឹតបន្តឹងតិចតួចបំផុត
- កាលបរិច្ឆេទនៃការពិនិត្យការបដិសេធសិទ្ធិឡើងវិញ ប្រសិនបើការបដិសេធនោះ ត្រូវបានពន្យារហួសពេល 30 ថ្ងៃ
- ហត្ថលេខារបស់អ្នកមានវិជ្ជាជីវៈ ដែលជាអ្នកទទួលខុសត្រូវចំពោះមន្ទីរថែទាំព្យាបាល ឬអ្នកដែលខ្លួនចាត់តាំងឲ្យទទួលខុសត្រូវចំពោះការបដិសេធសិទ្ធិរបស់អ្នកជម្ងឺ ។

**ការប្រគល់សិទ្ធិឲ្យអ្នកជម្ងឺវិញ**

នៅពេលដែលសិទ្ធិរបស់អ្នកជម្ងឺត្រូវបានបដិសេធរួចហើយ យើងត្រូវប្រគល់សិទ្ធិនោះឲ្យគាត់វិញជាបន្ទាន់នៅពេលដែលមូលហេតុនៃការបដិសេធនេះ លែងមានប្រសិទ្ធិភាពតទៅទៀត ។ 9 C.C.R. §§ 865, et seq ។ បុគ្គលិករបស់មន្ទីរក៏ត្រូវតាមដានការបដិសេធសិទ្ធិនីមួយៗនៅក្នុងកំណត់ត្រាព័ត៌មាននៃការព្យាបាលជម្ងឺរបស់អ្នកផងដែរ ។ WIC § 5326 ។ នៅពេលដែលសិទ្ធិណាមួយរបស់អ្នកជម្ងឺ ត្រូវបានបដិសេធ បុគ្គលិកមន្ទីរត្រូវប្រើវិធីគ្រប់គ្រងអាកប្បកិរិយារបស់អ្នកជម្ងឺដែលមានភាពរឹតបន្តឹងតិចតួចបំផុត ដែលនាំទៅរកការបដិសេធនេះ ។

ត្រង់នេះគឺមានន័យថា មន្ទីរថែទាំព្យាបាល មានកាតព្វកិច្ចក្នុងការវាយតម្លៃជាបន្តបន្ទាប់ថាតើ ការដិសេធសិទ្ធិរបស់អ្នកជម្ងឺ មានហេតុផលសមរម្យមែនដែរឬទេ ។ ឧទាហរណ៍ ប្រសិនបើ សិទ្ធិរបស់អ្នកជម្ងឺក្នុងការស្លៀកពាក់ខោអាវរបស់ខ្លួនត្រូវបានបដិសេធ ដោយសារតែមានការបារម្ភចំពោះការបង្ករបួសស្នាមចំពោះរូបគេ បុគ្គលិកមន្ទីរត្រូវផ្តល់ឱកាសដល់អ្នកជម្ងឺឲ្យបានញឹកញាប់ ក្នុងការបង្ហាញថា អ្នកជម្ងឺរូបនោះអាចពាក់ខោអាវរបស់ខ្លួនបានដោយមិនមានការបង្ករបួសស្នាមចំពោះខ្លួនឯងឡើយ ។

# ការទាក់ទងទៅកាន់អ្នកតស៊ូមតិដើម្បីសិទ្ធិអ្នកជម្ងឺ

អ្នកជម្ងឺមានសិទ្ធិមើល និងទទួលបានសេវាកម្មរបស់អ្នកតស៊ូមតិដើម្បីសិទ្ធិអ្នកជម្ងឺ (PRA, Patients’ Rights Advocate) ឬហៅកាត់ថា PRA ។ WIC § 5325 ។ PRA អាចជួយអប់រំអ្នកអំពីសិទ្ធិរបស់អ្នក ព្រមទាំងផ្តល់ដំបូន្មានអំពីជម្រើសដែលអ្នកមាន ចំពោះការព្យាបាលខ្លួនអ្នក ។ PRA ធ្វើការងារដោយឯករាជ្យពីមន្ទីរថែទាំព្យាបាល ឬបុគ្គលិកគ្លីនិក ហើយពួកគេធ្វើការសម្រាប់តែផលប្រយោជន៍របស់អ្នកជម្ងឺតែប៉ុណ្ណោះ ។

បើអ្នកមានចម្ងល់អំពីសិទ្ធិរបស់អ្នក ឬមានចម្ងល់អំពីជម្រើសនៃការព្យាបាល អ្នកអាចទាក់ទង PRA ដើម្បីសុំជំនួយ ។ អ្នកអាចសុំជួប PRA ដោយការទាក់ទងដោយផ្ទាល់មកកាន់ការិយាល័យ PRA ប្រចាំមន្ទីរព្យាបាលរបស់អ្នក ឬក៏ស្នើសុំបុគ្គលិកមន្ទីរឲ្យជួយអ្នកក្នុងការទាក់ទង PRA ។ នៅពេលអ្នកធ្វើការជាមួយ PRA គឺអ្នកមានសិទ្ធិជួបពួកគេជាលក្ខណៈឯកជន ដើម្បីពិភាក្សាអំពីបញ្ហានានាដែលអ្នកមានកង្វល់ ។

បើអ្នកមិនអាចទាក់ទងជាមួយនឹង PRA បាន អ្នកអាចទាក់ទងទៅកាន់ការិយាល័យសិទ្ធិអ្នក ជម្ងឺនៅរដ្ឋកាលីហ្វ័រនីញ៉ា តាមរយៈព័ត៌មានខាងក្រោម ៖

California Office of Patients’ Rights
1831 K Street
Sacramento, California 95811-4114
លេខទូរស័ព្ទ ៖ (916) 504-5810

យើងខ្ញុំចង់ស្តាប់យោបល់អ្នក! សូមជួយបំពេញសំណួរសម្រង់មតិខាងក្រោម ស្តីអំពីការបោះពុម្ពផ្សាយរបស់យើងខ្ញុំ ហើយប្រាប់ឱ្យយើងខ្ញុំបានដឹងពីគុណភាពការងាររបស់យើងខ្ញុំ! [ចាប់ផ្តើមបំពេញសំណួរសម្រង់មតិ]

សម្រាប់ជំនួយផ្លូវច្បាប់ សូមហៅមកលេខ 800-776-5746 ឬបំពេញ បែបបទស្នើសុំជំនួយ ។ សម្រាប់គោលបំណងផ្សេងៗទៀត សូមហៅទូរស័ព្ទមកលេខ 916-504-5800 (កាលីហ្វ័រនីញ៉ាខាងជើង) 213-213-8000 (កាលីហ្វ័រនីញ៉ាខាងត្បូង) ។

*Disability Rights California បានទទួលមូលនិធិឧបត្ថម្ភពីប្រភពផ្តល់ជំនួយមួយចំនួន ។ សម្រាប់បញ្ជីលម្អិតនៃអ្នកផ្តល់ជំនួយ សូមទស្សនាគេហទំព័រ*
http://www.disabilityrightsca.org/Documents/ListofGrantsAndContracts.html
។